**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មានអូស្ត្រាលី លើស្ថានភាពនយោបាយនៅកម្ពុជា

អូស្ត្រាលីមានក្តីបារម្ភចំពោះការវិវត្តន៍នាពេលថ្មីៗនៅកម្ពុជា ដែលបានគំរាមកំហែងដល់ការរឹតត្បឹតនៃលម្ហនយោបាយ ជាពិសេសសេរីភាពរបស់គណបក្សប្រឆាំង អង្គការសង្គមស៊ីវិល និងសារព័ត៌មាន ក្នុងការដើរតួនាទីរបស់ពួកគេក្នុងលទ្ធិប្រជាធិបតេយ្យដ៏ទូលំទូលាយនៅកម្ពុជា។ អូស្ត្រាលីមានក្តីបារម្ភជាពិសេសលើការចាប់ខ្លួនរបស់លោកកឹម សុខា ប្រធានគណបក្សប្រឆាំង សង្គ្រោះជាតិកម្ពុជា នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧។ ការចាប់ខ្លួននេះបង្ហាញនូវការវិវត្តន៍កាន់តែអាក្រក់ទៅនៃស្ថានភាពនយោបាយមុនពេលការបោះឆ្នោតជាតិនាខែកក្កដា ឆ្នាំ២០១៨ខាងមុខ។

យើងសូមជម្រុញអាជ្ញាធរកម្ពុជាឲ្យចាត់វិធានការណ៍ចាំបាច់នានាដើម្បីរក្សានូវលម្ហរលទ្ធិប្រជាធិបតេយ្យបើកចំហរ ដែលអាចឲ្យមានការបញ្ចេញនូវទស្សនៈផ្សេងៗ។ សេរីភាពនៃការបញ្ចេញមតិ និងការប្រមូលផ្តុំ សារពត៌មានដែលរស់រវើក និងបក្សប្រឆាំងដែលសកម្ម ជាធាតុផ្សំដ៏សំខាន់នៃដំណើរលទ្ធិប្រជាធិបតេយ្យប្រកបដោយជោគជ័យ។

ក្នុងនាមជាមិត្តភក្តិដ៏យូរអង្វែងរបស់កម្ពុជា អូស្ត្រាលីសូមជម្រុញដល់កម្ពុជាអនុវត្តយ៉ាងពេញលេញនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ ដូចដែលបានអះអាងក្នុងធម្មនុញ្ញអាស៊ាន និងគោរពសេរិភាពនៃការបញ្ចេញមតិ សមាគម និងការប្រមូលផ្តុំដោយសន្តិភាព។

**ទំនាក់ទំនងពត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au

**ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧**